JICA Cambodia Office - JICA カンボジア事務所
February 3 at 6:32 PM ·

**[កិច្ចប្រជុំគណៈកម្មការសម្របសម្រួលរួមលើកទី២ របស់គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាកនៅប្រទេសកម្ពុជា /**
**The 2nd Joint Coordination Committee (JCC) Meeting of the Project for Strengthening of In-Service Training System in Cambodia (The Strings)]**

------------------------------

**នាថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០២៣ ក្រសួងសុខាភិបាល និងគម្រោង JICA សម្រាប់ពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (Strings) បានសហការរៀបចំកិច្ចប្រជុំគណៈកម្មការសម្របសម្រួលរួមលើកទី២ ដោយជោគជ័យ នៅសណ្ឋាគារ សុខាភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនសុជាតិ អនុរដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល និងតំណាងសំខាន់ៗមកពីក្រសួងសុខាភិបាល ទីភ្នាក់ងារ JICA ប្រចាំប្រទេសកម្ពុជា ទីស្នាក់ការកណ្តាល JICA នៅប្រទេសជប៉ុន (តាមរយៈ Zoom) ស្ថានទូតជប៉ុន គណៈគិលានុបដ្ឋាកកម្ពុជា (CCN) សមាគមគិលានុបដ្ឋាកកម្ពុជា ( CAN) បណ្តាមន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងមន្ទីរពេទ្យបង្អែកនៅក្នុងខេត្តសាកល្បង (ខេត្តបាត់ដំបង និងខេត្តកំពង់ចាម)។**
**នៅក្នុងកិច្ចប្រជុំ មានការធ្វើបទបង្ហាញស្តីពីវឌ្ឍនភាពនៃសកម្មភាពផ្សេងៗរបស់គម្រោង (ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ២០២២)។ ជាទីគួរឲ្យកត់សម្គាល់ លទ្ធផលដែលបានរំពឹងទុករបស់គម្រោងដូចជា ការអភិវឌ្ឍគោលការណ៍ណែនាំជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ត្រូវបានសម្រេចដោយមានការយល់ព្រមជាផ្លូវការពីក្រសួងសុខាភិបាលកាលពីខែមុន និងបានធ្វើការផ្សព្វផ្សាយជាលើកដំបូងក្នុងឱកាសនៃកិច្ចប្រជុំនេះ។ សកម្មភាពដែលបានគ្រោងទុកសម្រាប់អាណត្តិបន្ទាប់ (ពីខែមករា ដល់ខែមិថុនា ឆ្នាំ ២០២៣) ត្រូវបានចែករំលែក ហើយកិច្ចពិភាក្សាយ៉ាងសកម្មលើការអភិវឌ្ឍផែនការ និងកម្មវិធីសិក្សារបស់សេចក្តីណែនាំជាតិ INSET ក៏ត្រូវបានរៀបចំឡើងផងដែរ។ ក្នុងអំឡុងពេលពិភាក្សា ប្រធានបទសម្រាប់ការបណ្តុះបណ្តាលដែលយើងគួរតែផ្តោតលើ និងការធានាលើគុណភាពនៃអ្នកផ្តល់ការបណ្តុះបណ្តាលនៅលើគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ត្រូវបានពិភាក្សាយ៉ាងសកម្ម។ សំខាន់ជាងនេះទៅទៀត សារៈសំខាន់នៃការអភិវឌ្ឍន៍គោលការណ៍ណែនាំប្រកបដោយប្រសិទ្ធភាពត្រូវបានបញ្ជាក់ឡើងវិញក្នុងចំណោមភាគីពាក់ព័ន្ធ៕**
**អត្ថបទ៖ អ៊ឹង សុដាវី , ក្រុមការងារគម្រោង Strings**

**On 1st Feburary 2023, the Ministry of Health (MoH) and the Strings project successfully co-organized the 2nd JCC at the Sokha Phnom Penh Hotel presided over by H.E. Prof. Mam Bunsocheat, Under Secretary of State for Health and also key representatives from MoH, JICA Cambodia Office, JICA Headquarter in Japan (via Zoom), Embassy of Japan, Cambodian Council of Nurses (CCN), Cambodian Association of Nurses (CAN), national hospitals, provincial administration health departments, provincial hospitals, and regional training centers in pilot provinces (Battambang & Kampong Cham).**
**At the meeting, the progress of various project activities (July-December. 2022) was reported. Remarkably, one of the expected project outputs, developing the National Guideline on In-Service Training for Nurses (INSET) was accomplished with the official approval by the MoH last month and disseminated for the first time with the occasion. The planned activities for the next term (Jan-Jun. 2023) were also shared. During the discussion, training topics we should focus on and how to ensure the quality of training providers on INSET were actively debated. Above all, the importance of effective INSET development was reconfirmed among the stakeholders.**
**Creditor: Oeng Sodavy, JICA Cambodia Office and Strings Project Team**












